ទាស់តែម្យ៉ាង គឺមន្ត ជាផ្នែកមួយនៃបេសកកម្មរបស់គេ។

«អ្នកឌីសាញល្បីម្នាក់ហ្នឹង នៅក្នុងឡានខ្ញុំ!»

វេហាចុចសារទៅក្រុមគេទាំងមានទំនុកចិត្ត រួចដៀងភ្នែកមករកប្រុសស្អាតខ្មែរ-អាមេរិកដែលត្រូវសុរាគេងចំហមាត់។ ឫកពាបែបណាក៏នៅតែ....ស្អាត។

គេមិនដាច់ចិត្តថតរូបភាពនេះផ្ញើទៅជាព័ស្តុតាងទេ ទោះមុននេះគេចង់ផ្ញើ តែបេះដូងនេះមានអារម្មណ៍ថាធ្វើខុសៗចំពោះ«មន្ត»។

ម្រាមគេរាវរកលេខអ្នកក្រឡុកស្រា ហើយចុចសារ«ដាក់កម្រិតណាបានជាគេឡើងដល់ឡានភ្លាមគេងភ្លឹងនៀក? ក្រោកវិញអត់មើលទៅ?»។

«ដាក់មួយកម្លាំងដែលបងវេហាអាចលេងបានដោយសុវត្ថិភាព! កុំភ្លេចABAខ្ញុំ បងឯងមានហើយ!» ឡង់ឌីតបមកវិញភ្លាម។

កុម្ភៈវក់នឹងភ្លើងពណ៌ ទុកឱ្យមន្តចូលអន្ទាក់កាចមួយ នេះជាអ្វីដែលវេហាគិតពេលដាក់ទូរសព្ទចុះ។ តែអន្ទាក់កាចមួយនេះគ្រោះឬលាភ វេហាជាម្ចាស់ចាត់ចែង។

«ក្មេងស្អាតនេះ មិនគួរឱ្យព្រនង់ទេ គួរឱ្យទឹកឃ្មុំ!»

គេគិតហើយក៏ដៀងមកមើលមន្តទៀត។ ទោះតាំងចិត្តថា នឹងផ្តង់អារម្មណ៍ឱ្យដល់កន្លែងលែងរវើរវាយ តែគំនិតនៅតែចាញ់ចិត្ត។

វេហាហៅ Lambda អាយុ៣១ឆ្នាំ អគ្គនាយកនៃក្រុមហ៊ុនចេនឡា១២ប្រេន Chenla12Brand បានកំណត់មុខសញ្ញាស្វែងរកនាយ មឿន រ៉ាម៉ុន ហៅមន្ត អាយុ២៦ឆ្នាំ អ្នកជំនាញផ្នែកច្នៃម៉ូត និងជា **Creative Director** របស់ **Warehouse USA**។ មិនមែនថា ចេនឡា១២មិនមានអ្នកជំនាញច្នៃម៉ូតអ៊ីតាលី ឬជប៉ុនទេ តែគូប្រជែងរបស់ចេនឡាកំពុងតាមរកយុវជនខ្មែរអាមេរិកនេះ ដូច្នេះវេហាត្រូវដើរមុនមួយជំហាន។

ទូរសព្ទរោទ៍....

គេធុញព្រោះស្គាល់លេខ តែធុញបែបណាក៏បង្ខំចិត្តចុចទទួល។

«ជម្រាបសួរអ្នកមីង»

«ត្រីស៊ីនុយហើយ?»

ប្រុសស្អាតងៀងមកមើលអ្នកឪហ្សាញកម្សត់ដែលរងជាតិថ្នាំរបស់ឡង់ឌី ដកដង្ហើមស្រណុកសុខស្រួលភ្លេចអស់ពិភពលោកជុំវិញ។ គេដែលធ្វើការថ្លោះធ្លោយពីពេលណា?

វេហាញាក់ស្មា មិនអាចចរចាច្រើនទេខ្លាចមន្តព្ទ គេតបខ្លី៖

«បាទ!»

«អូខេ! ធ្វើការល្អណាស់! ស្អែកព្រឹកសង្ឃឹមមានរូបភាពល្អចេញផ្សាយ!»

វេហាវភ្នែកគិត។

ល្បឿនរថយន្តនឹង តែចិត្តគេមិននឹងនរទេ។ ម្ដាយមីងជាប្រធានធំ President នៃចេនឡា១២ អន្ទះសាចង់ឱ្យគូប្រជែងឃើញរូបភាពអ្នកឪហ្សាញខ្មែរអាមេរិកធ្លាក់ក្នុងដៃវេហា ឬហៅបានថា ក្រុមហ៊ុនទាំងមូលចាប់បានមន្តម្នាក់នេះហើយ។

វេហាយល់ថា ចេនឡា១២ចង់បំបាក់ដៃគូធំរបស់គេ ដោយបំផ្លាញរូបភាពឯកជនរបស់អ្នកឪហ្សាញតូច។ គេដាច់ចិត្តទេ យកខ្លួនក្មេងប្រុសនេះហើយបង្ហាញរូបភាពគេជាសាធារណៈពេលអង្គុយអាហារពេលព្រឹកនៅវ៉េរ៉ង់ដាជាមួយខ្លួនព្រឹកស្អែក?

«មិនទាន់គិតទេអ្នកមីង!»

គេតបថ្មមៗ។

«មានន័យម៉េចក្មួយសម្លាញ់?»

សំឡេងគាត់សួរមកមិនសប្បាយចិត្ត តែក៏មិនហ៊ានលេងសព្ទខ្លាំងក្នុងបន្ទាត់សំឡេងតឹងតែងអ្វីជាមួយជាមួយអគ្គនាយកដែរ។

វេហាដឹងថាគេកំពុងធ្វើអ្វី និងត្រូវធ្វើអ្វី។ អ្នកដែលចង់គ្រប់គ្រងគេ ត្រូវស្គាល់ចរិតនៃការសម្រេចចិត្តឯករាជ្យរបស់គេ។

«បានន័យថា! របស់ល្អជាកម្មសិទ្ធិរបស់ខ្ញុំ! កម្មសិទ្ធិរបស់ខ្ញុំនៅក្រោមការគ្រប់គ្រងនិងសម្រេចចិត្តដោយខ្ញុំខ្លួនឯង!»

ប្រុសស្អាតឆ្លើយតបដោយទំនុកចិត្ត។

មិនតែប៉ុណ្ណោះ ដូចជាមិនរង់ចាំឱ្យម្ចាស់ក្រុមហ៊ុននិយាយបានបន្ត គេប្រញាប់បញ្ចប់៖

«រាត្រីសួស្តី!»

វេហាចុចបិទ។ ដាក់ទូរសព្ទចុះ គេវាក់ភ្នែកនឹងម្រាមដៃវែងៗ សរលោង និងខ្សែអង្កាំតូចៗពណ៌ទឹកឃ្មុំ។ ក្បែរនោះមានខ្សែមួយចំនួនទៀត សមឥតខ្ចោះនឹងកំភួនដៃណែនៗរបស់មន្ត។

ម្រាមនេះឯងដែលបានគូសវាសច្នៃម៉ូតជាច្រើនយ៉ាងល្បីល្បាញនៅអាមេរិក?

មន្តអត់មានចិញ្ចៀនមួយវង់ណាទេ។ តើអ្នកណាអាចពាក់ចិញ្ចៀនតូចស្ដើងមួយលើម្រាមនាងដៃឱ្យគេទៅ?

នេះហើយចរិតគិតអន្លាយវែងឆ្ងាយរបស់វេហា។ បេះដូងនេះចូលចិត្តសិល្បៈឪហ្សាញ ហើយក៏ចូលចិត្តមនុស្សប្រភេទស្អាតៗ ឡូយៗ សុភាពៗដូចមន្ត តែស្ដង់ដានេះមិនមែនងាយរកបាននៅភ្នំពេញទេ។

វេហាញញឹមតិចបំផុត....ជាស្នាមញញឹមតែម្នាក់ឯង ប៉ុន្តែបេះដូងគេដឹងថា គេកំពុងតែសប្បាយចិត្តចម្លែក។

## មណីនិល ហៅ Aziel

សក់ក្រាស់ពណ៌ត្នោត មាឌត្រឡោក ភ្នែកមុត រោមភ្នែកវែង បបូរមាត់ក្រាស់ទាំងលើនិងក្រោម ថ្ពាល់ស្លេកៗចង្កាទ្រវែងណែនទៅដោយសាច់ ដូចជនជាតិអង់គ្លេស ជាសម្រស់ត្រជាក់ល្ហឹមរបស់គេ។

មណីនិល ហៅ AZIEL អង្គុយសម្លឹងមើលឯកសារដែលជំនួយកាយឈ្មោះ ម៉ាន បាញ់មកឱ្យពិនិត្យទាំងយប់។ មនុស្សជាច្រើនដឹងថា AZIEL នៅនឹងការិយាល័យលើផ្ទះរបស់គេនៅឡើយពេលថ្មើរណេះ។

«ចេនឡា១២ជំពាក់Agencyជាង៤លានដុល្លារហើយ បើលើកនេះមិនអាចយកកុងត្រារបស់RAEទេ គេនឹងអាច....ដួល!»

AZIEL ញាក់ស្មាដូចជាកំពុងសើច តែមុខគេស្មើដដែល។ អ្វីមួយរត់ភ្លឹបក្នុងគំនិតបុរសនេះ

«AZIELជាអ្នកសាហាវ លើសង្វៀនពាណិជ្ជកម្ម! យើងមានវត្តមានមកយកជីវិតក្រុមហ៊ុនពួកគេ មិនមែនមកសង្គ្រោះទេ!»

ជាថ្មីម្ដងទៀត ភ្នែករបស់គេរេមកឃើញឯកសារទីពីរជារូបថត។

«មឿន រ៉ាម៉ុន អ្នកច្នៃម៉ូតមកពីអាមេរិក! ជាខ្មែរអាមេរិក! មុននេះ គ្នាយើងឃើញវេហាដឹកឡានចេញពីបារGays»

អង្គុយត្រង់ខ្លួនមកវិញភ្លាម ម្រាមដៃគេចុច Search ។ «មឿន វ៉ាម៉ុន-មន្ត កើតថ្ងៃទី១៥ ខែសីហា ឆ្នាំ១៩៩៨ ជាអ្នកច្នៃម៉ូតសម្លៀកបំពាក់នារី ដ៏ល្បីជាមួយនឹង Warehouse USA ។ ស្នាដៃដ៏ស្រស់ស្អាតរបស់នាយជាច្រើនត្រូវបានគេចាត់ទុកថាជាកំពូលវិជ្ជាជីវៈ និងសិល្បៈនៃការតុបតែងសម្រាប់អនាគតកាល។»

ម្រាមចង្អុលដៃស្តាំAZIELដាក់មកលើបបូរមាត់។ សន្លឹករូបថតទាំងអស់របស់មន្ត រួមទាំងអាល់ប៊ុមម៉ូតខោអាវរបស់គេ កំពុងខាបយកដង្ហើមស្ងប់ស្ងាត់របស់ម្ចាស់ជំនួញនៃអាណាចក្រ Top Aziel។ ទូរសព្ទដៃគេលោតសារមកបន្ថែម។

«ជនជាតិអាមេរិកកាំងដើមកំណើតខ្មែរម្នាក់នេះ ក៏ត្រូវបានគេស្គាល់ផងដែរ សម្រាប់ការរចនាឈុតអលង្ការច្រើនជាងគេក្នុងចំណោមអ្នកច្នៃម៉ូតថ្វាយរាជវង្សក្សត្រនៅឌូបៃ»

ជំនួយការសរសេរសារនេះ ហាក់ធ្វើឱ្យទ្រូងគេផ្ទុះ។ ជំនួសឱ្យការបញ្ចេញកំហឹង គេដកដង្ហើមធំលើកទូរសព្ទមកថតសំឡេងជាសំណួរ៖

«ហើយ.....បើអ៊ីចឹងមែន ម៉េចយើងបណ្តោយឱ្យអ្នកច្នៃម៉ូតម្នាក់ហ្នឹង ធ្លាក់ទៅក្នុងដៃពួកចេនឡា?»

«គេលេងល្បែងបំភាន់! សូម្បីជើងហោះហើរ ឬថ្ងៃមកដល់ភ្នំពេញ អត្តសញ្ញាណជួលសណ្ឋាគារគេងបន្លំទាំងអស់!»

ចៅហ្វាយផ្អៀងកទៅមួយចំហៀងនៃបង្អែកលើកៅអី ភ្នែកក្រឡេកទៅក្រៅបង្អួចនៃបន្ទប់ខុនដូរខ្ពស់សន្លឹម។ ថ្មើរណេះ ភ្នំពេញលង់លក់ក្រោមរាត្រីកាលហើយ ក្មេងប្រុសនោះត្រូវជនឈ្មោះវេហានាំទៅណា?

Aziel ស្គាល់ព្រាន Lambdaច្បាស់។ មនុស្សនេះជាន់ផ្អៀងចេនឡា១២ ព្រោះតែម្តាយមីងគេដែលជាអ្នកមានអំណាចក្នុងជួររដ្ឋការ ថែមមានភាគហ៊ុនធំនៅទីនោះ តែខ្លួនគេវិញ បើមិនដើរឱបប្រុសៗដូរមុខដូចខោអាវ គឺដើរផឹកស៊ីនៅបារថ្លៃៗមិនរំលងឱ្យទំនេរមួយយប់ណាទេ។

«វេហាអាចជួលមនុស្សទាំងអស់ បង្វែរពីដំណឹងរបស់អ្នកឌីហ្សាញម្នាក់នេះ! អាចថា សូម្បីមនុស្សជុំវិញគេ ក៏ត្រូវបានទិញដែរAziel!» ជាចំណារបន្ថែមមកទៀតរបស់ម៉ាន។

Aziel ងក់ក្បាល ហើយលើកនាឡិកាដៃមើលម៉ោង។ ម៉ោង០១និង២៨នាទីរំលងអធ្រាត្រហើយ ។ គេងក់ក្បាលម្នាក់ឯងដូចជាកំពុងតែយល់ព្រមស្ងាត់លើកិច្ចព្រមព្រៀងអ្វីមួយ។

បន្ទាប់មក គេបញ្ជាទៅទៀតដោយសំឡេង៖

«រកកន្លែងដែលវេហានាំក្មេងនោះទៅ!»

«បាទ!»

## កុម្ភៈ ហៅប្រធានទីផ្សារបារាំង

«អេក៎កុម្ភៈ!»

កុម្ភៈស្ងាងស្រវឹងពេលឮសំឡេងហៅ។

គេឈប់ដៃក្បែរស៊ីងលាងដៃ ដោយមិនទាន់ងាកមកឬបិទទឹកឡើយ។

កែវភ្នែកវិលមួយជុំភ័យ....គេឃើញស្នាមញញឹមដ៏កាចមួយពីក្រោយខ្នង។

«ម៉ាន?»

«បារាំងទៅណាអស់ហើយ?»

«គ្មានទេ!» កុម្ភៈឆ្លើយទាំងក្រឡេកឆ្វេងស្តាំរកមើលមនុស្ស។

«គ្មានអ្នកណាមកក្នុងនេះបានទេ គ្នាយើងបិទពីក្រៅហើយ!» ម៉ាននិយាយព្រមានដោយងើយមុខកាចៗដាក់។

«អ្នកលេងសង្គមងងឹតហ្មែន ធ្វើមើលតែក្នុងកុន!»

កុម្ភៈរអ៊ូក្រញូវ បិទទឹកនិងទាញក្រដាសមកជូតដៃ។

ងាកមកមិនទាន់បានតវ៉ាទៀតផង ទូរសព្ទកំពុងហុចមក។ លើអេក្រង់មានផ្ទៃមុខដ៏មានមន្តស្នេហ៍មួយកំពុងឈ្ងោកធ្វើអ្វីម្យ៉ាង បង្ហាញឃើញតែច្រមុះស្រួចនិងចិញ្ចើមកាចៗ។

«បងនិល!»

កុម្ភៈហៅតិចៗទាំងថ្លោះទឹកមុខ។

Aziel ងើបមុខពេលឮកុម្ភៈហៅឈ្មោះ។ គេកម្រើកផ្នែកខាងលើនៃបបូរមាត់បន្តិច តែមិនបានញញឹមទេ។

«សុខសប្បាយ?» សំឡេង Aziel ធម្មតា តែបំពង់ករបស់កុម្ភៈស្ងួតច្រើងភ្លាមៗ។ អួលហើយ! រកពាក្យតបមិនបានភ្លាមៗទេ ព្រោះគេដឹងថា ហេតុអ្វីបានជាកូនចៅ Aziel នៅទីនេះហើយគេខ្លួនឯងចំណាយពេលខលវីដេអូមក។

«បងនិល! មន្តអត់នៅជាមួយខ្ញុំទេ!»

និលឬAzielឈ្ងោកមុខដូចកំពុងញញឹមចំអក។

មាត់គេបញ្ចេញសំណួរ៖

«អ៊ីចឹងនៅជាមួយអ្នកណា?»

«អត់...អត់ច្បាស់ទេបង ចាំ...ចាំចេញទៅ ខ្ញុំខលសួរឱ្យ!»

«ឱ្យលេខមក!»

គេភាំង។

សំឡេងម៉ានសម្លុតតិចៗពីក្រៅដោយខាំមាត់៖

«លេខខ្មែររបស់មឿន រ៉ាម៉ុន!»

កុម្ភៈសម្លឹងមុខមនុស្សក្នុងទូរសព្ទដែលស្មើៗដូចគ្មានរឿងអ្វីរំខាន តែគេដឹងថា គេមិនអាចប្រកែកជាមួយសំណើរនេះទេ។

គេរាវរកទូសព្ទ ហើយចុចបើកមើល។

គ្រឹប! ម៉ានថតS creen របស់គេ។

«ខ្ញុំ....ខ្ញុំងងុយណាស់បង ខ្ញុំសុំទៅមុនហើយ!»

ប្រុងតែបែរចេញរកទ្វារ ត្រចៀកឮសំណួរចេញពីទូរសព្ទ៖

«កាលមុន ឯងសន្យាថា ឱ្យតែអ្នកឪហ្សាញធំៗមកស្រុកខ្មែរ នឹងយកមកឱ្យបង!»

កុម្ភៈលេបទឹកមាត់ភ័យ ហើយងាកមកវិញ។ បិសាចមុខស្រស់ដែលមនុស្សជាច្រើនខ្លាចគេ កំពុងសម្លឹងមក។ បើមិនញញើតចំពោះសកម្មភាពឥតមេត្តារបស់គេ កុម្ភៈលង់សម្រស់គេបាត់ហើយ។

«មកពី....ប្អូន....ប្អូនយល់ថា រ៉ាម៉ុនជាអ្នកច្នៃម៉ូតល្បីតិចតួច! ធម្មតាៗ»

«ប្រាប់ចំនួនទឹកលុយរបស់ចេនឡា១២មក?» និលឬហៅថា Aziel និយាយខ្លីៗបញ្ចប់គំនិតឆ្កួតៗរបស់កុម្ភៈដែលចង់យករួចខ្លួន។

ជននេះបានលេងល្បិចច្រើនគន្លាក់ក្នុងការបង្វែរមន្តឱ្យដូរជើងយន្តហោះ ដូរថ្ងៃមកភ្នំពេញ និងនាំគេមកកន្លែងនេះ ចូលស៊ងរបស់វេហា ព្រោះគេពិតជាទទួលបានប្រាក់សំណូកពីចេនឡា១២ពិតប្រាកដមែន។

មិនថា អ្នកណាមានជាងអ្នកណា ឱ្យតែទំហំលុយធំជាង កុម្ភៈត្រូវតែរេ ព្រោះគេមានសង្សារបារាំងច្រើន ចូលចិត្តទិញរបស់ប្រេនៗនិងមានវិបត្តិបំណុលក្រេឌីត។

សម្លុតរបស់Aziel កំពុងធ្វើឱ្យសរសៃប្រសាទរបស់គេកើនភាពតឹងតែងឡើងដល់កម្រិតខ្ពស់ ហើយបញ្ជូនរលកនៃការភ័យស្លន់ស្លោមកដល់មាត់គេ។

ការចងចាំដែលធ្លាប់ស្គាល់ គឺគេអត់ការងារធ្វើសឹងអត់ឃ្លានដោយសារបុរសនេះ លូកដៃកកូរពាណិជ្ជកម្មនានាជុំវិញហ្វេស្ទិននៅស្រុកខ្មែរបាន។ បាតដៃនិលធំណាស់ ប្រសិនគេឱ្យកុម្ភៈអត់ការងារធ្វើ ប្រាកដណាស់ គ្មានអ្នកណាហ៊ានទទួលយកប្រធានទីផ្សារម្នាក់នេះផ្តើនចិត្តនិល។

អំពីការសម្លឹងរបស់គេ មកលើកុម្ភៈ ធ្វើឱ្យកុម្ភៈលែងចង់គេចវេះ។

គេឈ្ងោកមុខដូចក្មេងទទួលកំហុសហើយតបក្បួរៗ៖

«៥ពាន់ដុល្លារអាមេរិកបង! បងនិល....មកពីខ្ញុំ....ជាប់បំណុល....»

«ឱ្យវា៨ពាន់ ហើយប្រាប់កន្លែងអាប៉ិLambdaមកឥឡូវ!»

ម្រាមដៃដ៏ធំនិងវែង Aziel លូកមកចុចបិទអេក្រង់។

លិឍបបូរមាត់ភ័យ កុម្ភៈឮសូរស្នូរធនាគារផ្ទេរលុយចូលមកក្នុងAccountគេហើយ។ គេមិនដឹងត្រូវដោះស្រាយជាមួយវេហាវិធីណាទេ តែជាមួយAziel គេរឹតតែញាក់ប្រាណភ័យ។

«លុយបានហើយ! ឱ្យអាសយដ្ឋានមក!»

**អាណាចក្រTopAziel**

មុននេះ២០ម៉ោង.....

«Aziel លោកអ៊ំមកក្រុមហ៊ុន!»

សម្ដីរបស់ជំនួយការឈ្មោះម៉ាន ធ្វើឱ្យCEOភ្ញាក់។ គេលើកនាឡិការ៉ូឡិចមកមើល។ ម៉ោងជិត៩យប់ហើយ ម៉េចប៉ាគេដឹងថាគេនៅក្រុមហ៊ុននិងឡើងមកទីនេះ?

គេទាញតម្រង់ក្រវាត់កស្រេបពេលម៉ានប្រាប់បន្ថែម៖

«នៅបន្ទប់ប្រជុំតូច!»

ប្រុសស្អាតដើរទៅកាន់ទីនោះដោយស្ងាត់ស្ងៀមតែជំហាននឹងធឹង។ Aziel តែងតែចងចាំរូបភាពនីមួយៗពេលប៉ាគេឡើងមកក្រុមហ៊ុន ដោយមិនជូនដំណឹង។

ជាញឹកញាប់ គាត់មានបញ្ហាសម្ពាធពីអ្នកនយោបាយ ពីសេដ្ឋីផ្សេងៗ ឬអាចជារឿងរើសកូនប្រសាឱ្យគេ។ តែក្នុងរយៈពេល២ឆ្នាំចុងក្រោយនេះ គេមិនដែលឃើញប៉ាគេមកការិយាល័យតក់ក្រហល់បែបនេះឡើយព្រោះគេបានធ្វើឱ្យគ្រប់យ៉ាងរៀបរយ។

ហើយ...ពេលដែលឈានមិនទាន់ដល់ទ្វារផង ជីពចររបស់គេបែរទៅជាលោតញាប់.....វាជាអាការៈចាស់! ជាអាការៈដែលខានកើតមាន៦ឆ្នាំមកហើយចាប់តាំងពីគេ.....បាត់បង់នាង។

គេឈប់ជើងង៉ក់ហើយងាកមកសម្លឹងម៉ានដោយកែវភ្នែកក្ដៅក្រហាយ....ជំនួយការដែលមានវ័យមិនលើសខ្វះគ្នាឈ្ងោកមុខដឹងកំហុស និងរអ៊ូៗ៖

«ខ្ញុំ.....គឺ....លោកអ៊ំ ហាមមិនឱ្យប្រាប់Azielថា ម៉ាលីសមកដែរ!»

ឈ្មោះនាង ក្នុងចិត្តខ្ញុំនិលម្នាក់នេះ ស្លាប់បាត់ទៅហើយ តែព្រលឹងនៅអន្ទោល។...គេងាកមុខចេញពីជំនួយការ។ មាត់គេហា អណ្ដាតគេរឹល រកទំនុកស្រាយស្ថានការណ៍ចំពោះមុខ។

Aziel ចង់ឱ្យគ្រប់គ្នាយល់ថា អតីតរវាងគេនិងនាងជា«សំរាម» ដែលមានក្លិននិងគ្មានអ្នកណាចង់រំឭកដល់។

តែពេលនេះ ម៉ាលីស ឡើងមកជាមួយប៉ារបស់គេ....